**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Aug-2011, 11:36
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អជសដ
ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីលោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬអង្គជំនុំជម្រះ: **សាធារណៈ/Public**
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី សុំអនុញ្ញាតឆ្លើយតប ឬសុំឲ្យមានសវនាការផ្ទាល់មាត់**
**និង**
**ការឆ្លើយតបទៅនឹង "ចម្លើយតប" របស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ជាជាងក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

---

<u>ដាក់ដោយ</u>៖
**សហមេធាវីរបស់លោក អៀង សារី៖**
អាង ឧត្តម
Michael G. KARNAVAS

<u>ផ្ញើជូន</u>៖
**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន
ចៅក្រម ធូ មណី
ចៅក្រម យ៉ា សុខន
ចៅក្រម Silvia CARTWRIGHT

---

ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង យូរ ឧត្តរា
ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# សំណើសុំអនុញ្ញាតឆ្លើយតប

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ (“សហមេធាវីការពារក្តី”) ស្នើសុំការអនុញ្ញាតឆ្លើយតបទៅនឹងចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាអំពើរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (“ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)[១]។ ការឆ្លើយតបនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវអំណះអំណាងថ្មីៗដូចខាងក្រោមដែលអំណះអំណាងទាំងនោះមិនត្រូវបានលើកឡើងដោយ ក.ស.ព នៅក្នុងសំណើរបស់ ក.ស.ព[២]៖ **ក.**“ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានតុលាការយោធាអន្តរជាតិចាត់ទុកថាជាឧក្រិដ្ឋកម្មដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា”[៣] **ខ.**“នៅពេលនោះ វាច្បាស់លាស់ណាស់ថា ការរំលោភសេពសន្ថវៈគឺជាបទល្មើសមួយ ដែលគ្រប់ប្រជាជាតិទាំងអស់អាចផ្តន្ទាទោសបាននៅក្នុងយុត្តាធិការជាតិរបស់ខ្លួន និងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងជាក់លាក់”[៤] **គ.**“បញ្ជីឈ្មោះ “សមាជិកពេញសិទ្ធិ និងសមាជិកបម្រុងរបស់តុលាការ” និង “មេធាវីដើមបណ្តឹង” [របស់តុលាការយោធាអន្តរជាតិ] ពុំមានអ្នកចូលរួមជាស្ត្រីភេទទេ... ដែលជាកត្តាសំខាន់នៅក្នុងការមិនបញ្ចូលអំពើរំលោភសេពសន្ថវៈថាជា

---

[១] ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុ ដែលធ្វើឲ្យការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈក្លាយជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E99/1។

[២] សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គបុរេជំនុំជម្រះសាលាដំបូងកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាអំពើរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E99។

[៣] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ១៤។ *សូមមើលផងដែរ ដូចដើងទំព័រខាងលើ* កថាខណ្ឌ១០៖ “បទឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានលក្ខណៈរួមគ្នាគឺថា បទល្មើសទាំងពីរនេះជាបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរ និងជាក់លាក់ជាងគេ”។ *ដូចដើងទំព័រខាងលើ* កថាខណ្ឌ២៦៖ “អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជាបទឧក្រិដ្ឋសង្គ្រាមនៅក្នុងបណ្តាយុត្តាធិការតុលាការជាតិ នៅតាមប្រទេសជាច្រើននៅត្រឹមឆ្នាំ ១៩៧៥”។

[៤] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ១៦។ *សូមមើលផងដែរ ដូចដើងទំព័រខាងលើ*, កថាខណ្ឌ១៩៖ “អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់នៅក្នុងយុត្តាធិការតុលាការជាតិ នៅទូទាំងពិភពលោកជាបទឧក្រិដ្ឋមានលក្ខណៈ និងគួរឲ្យស្អប់ខ្ពើម ហើយត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋសង្គ្រាមមួយ ដែលយ៉ាងហោចណាស់ក៏ចាប់តាំងពីឆ្នាំ ១៩១៩ ដែរ”។ *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ២០៖ “ការជំនុំជម្រះទោសទៅលើអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានធ្វើឡើងមកហើយនៅក្នុងយុត្តាធិការតុលាការជាតិ នៅដើមទសវត្សរ៍ឆ្នាំ ១៩០០”។ *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ២៦៖ “អំពើរំលោភសេពសន្ថវៈជាបទល្មើសមួយដែលទទួលស្គាល់ទូទាំងពិភពលោក ក្នុងចំណោមបណ្តាយុត្តាធិការតុលាការជាតិនៃប្រទេសនានា”។

ឧក្រិដ្ឋកម្ម ដែលមានរាយឈ្មោះក្នុងបញ្ជីថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[៥] **ឃ.**“នៅក្នុងអំឡុងពេល [បួនឆ្នាំចន្លោះពេលអនុម័តធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងការបញ្ចូលការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុង ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង [(“CCL លេខ ១០”)] ពុំមានការរីកចម្រើននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងពន្យល់ពីការប្រែប្រួលនេះទេ ដូច្នេះហើយ គេអាចសន្និដ្ឋានបានថា ការមិនបញ្ចូលអំពើរំលោភសេពសន្ថវៈនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ មិនមែនជាការបង្ហាញថា គ្មានអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅខែ សីហា ឆ្នាំ ១៩៤៥ នោះទេ”[៦] និង **ង.**អំពើរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គួរត្រូវបានកំណត់បទចោទសាជាថ្មីឡើងវិញ ដើម្បីឆ្លុះបញ្ចាំងពីការប្រើប្រាស់អំពើរំលោភសេពសន្ថវៈថាជាផ្នែកមួយនៃ “គោលនយោបាយខ្មាំងសត្រូវ” មួយ[៧]។ ដើម្បីជាប្រយោជន៍ខាងសេដ្ឋកិច្ចផង និងពេលវេលាផង មេធាវីការពារក្តីបានភ្ជាប់ការឆ្លើយតបរបស់ខ្លួនមកជាមួយដែរ។ ទាំងសំណើសុំការអនុញ្ញាតដាក់ការឆ្លើយតប និងការឆ្លើយតប ត្រូវបានដាក់នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១១ ដែលជាកាលបរិច្ឆេទចុងក្រោយដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង សម្រាប់ឲ្យ ក.ស.ព ធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី[៨]។ ក្នុងករណីដែលការឆ្លើយតបនេះត្រូវបានបដិសេធចោលនោះ មេធាវីការពារក្តីសូមស្នើដោយគោរពសុំឲ្យមានសវនាការដោយផ្ទាល់មាត់ជាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងសារណាដែលបានដាក់ជូននាពេលថ្មីៗដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបញ្ហាដទៃដែលអង្គជំនុំជម្រះសាលាដំបូងអាចយល់ថាជាការចាំបាច់ពាក់ព័ន្ធនឹងបញ្ហាដែលថា តើអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងពេលនៃយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក ឬទេ។

## ឧទ្ធិករណ៍

---

[៥] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ១៧។

[៦] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ១៨-១៩។

[៧] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៣២-៤១។

[៨] សេចក្តីសម្រេចលើពាក្យសុំពន្យារពេល ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E107។

១. ទឡ្ហីករណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីធ្វើឡើងហួសពីការអះអាងរបស់ខ្លួនដែលថា ខ្លួនបានបន្ថែម “ទឡ្ហីករណ៍បន្ថែមមួយចំនួន ដើម្បីគាំទ្រដល់ការអះអាងថា អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់រួចហើយ ថាជាឧក្រិដ្ឋកម្មដែលស្ថិតក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានរាយឈ្មោះក្នុងបញ្ជីនៅក្នុងពេលពាក់ព័ន្ធ”[៩]។ “ទឡ្ហីករណ៍បន្ថែម”ទាំងអស់នេះ គឺជាទឡ្ហីករណ៍នៅដែលបានដាក់ក្នុងសារណាដំបូងរួចហើយ។ សហមេធាវីការពារក្តីត្រូវតែទទួលបានការអនុញ្ញាតឲ្យធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍ទាំងអស់នេះ។

២. ដោយសារតែចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានទឡ្ហីករណ៍ ដែលមាននៅក្នុងសារណាដំបូងរួចហើយនោះ ដូចនេះទឡ្ហីករណ៍ទាំងនោះមិនអាចត្រូវបានចាត់ទុកថា បានលើកឡើងនៅក្នុងចម្លើយតបរបស់សហមេធាវីការពារក្តីទៅនឹងសំណើរបស់ ក.ស.ព ឡើយ[១០]។ សហមេធាវីការពារក្តីមានសិទ្ធិឆ្លើយតបទៅនឹងសារណាទាំងអស់នេះ ដើម្បីឲ្យសិទ្ធិជាមូលដ្ឋាននៃសមភាពក្នុងការតទល់ក្នុងរឿងក្តីរបស់លោក អៀង សារី ត្រូវបានគោរព។ តុលាការសិទ្ធិមនុស្សអឺរ៉ុប (“ECHR”) បានរកឃើញថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ត្រូវបានរំលោភនៅពេលដែលអ្នកដាក់ពាក្យសុំត្រូវបានបដិសេធ មិនផ្តល់ឱកាសឲ្យធ្វើការឆ្លើយតបទៅនឹងសារណាជាលាយលក្ខណ៍អក្សរ ដែលបានដាក់ដោយក្រុមប្រឹក្សារដ្ឋ[១១]។ នៅក្នុងរឿងក្តី *Ruiz-Mateos តទល់នឹង ប្រទេសអេស្ប៉ាញ* អ្នកដាក់ពាក្យសុំបានលើកឡើង អំពីការរំលោភលើគោលការណ៍សមភាពក្នុងការតទល់ក្នុងរឿងក្តី ដោយហេតុថា ក្រុមប្រឹក្សាសម្រាប់រដ្ឋាភិបាលអេស្ប៉ាញ គូបដិបក្ខនៅក្នុងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី អាចដាក់ជូនតុលាការធម្មនុញ្ញនូវសេចក្តីសង្កេតជាលាយលក្ខណ៍អក្សរស្តីពីភាពស្របច្បាប់នៃលក្ខន្តិកៈមួយបាន ប៉ុន្តែពួកគាត់មិនត្រូវបានអនុញ្ញាតឲ្យដាក់ការអង្កេតទាំងនោះទេ ពីព្រោះសេចក្តីសង្កេត ទាំងនោះត្រូវបានលើកឡើង ថាគ្មាន *សិទ្ធិ*

[៩] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ៤។

[១០] ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងបទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុដែលធ្វើឲ្យការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត, ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

[១១] *រឿងក្តី Ruiz-Mateos តទល់នឹង ប្រទេសអេស្ប៉ាញ*, តុលាការសិទ្ធិមនុស្សអឺរ៉ុប, សំណុំរឿងលេខ 16 E.H.R.R. 505, សាលក្រម, ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៣, ពាក្យសុំលេខ 12952/87 កថាខណ្ឌ៦៣-៦៨។

*របស់ភាគីមួយក្នុងការចូលរួម និងផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ (locus standi)*[១២]។ តុលាការសិទ្ធិមនុស្សអឺរ៉ុបយល់ឃើញថា "ជាបទដ្ឋាន ជនទាំងឡាយត្រូវទទួលបានការធានាក្នុងការដឹងដោយសេរី អំពីសេចក្តីសង្កេតនានារបស់អ្នកចូលរួមផ្សេងទៀតនៅក្នុងកិច្ចដំណើរការនីតិវិធីទាំងអស់នេះ និងឱកាសពិតប្រាកដមួយក្នុងការផ្តល់យោបល់លើសេចក្តីសង្កេតទាំងអស់នោះ"[១៣]។ ករណីនេះស្រដៀងគ្នាទៅនឹងសេណារីយ៉ូដែលលោក អៀង សារី បានជួបប្រទះ ពីព្រោះប្រសិនបើការឆ្លើយតបនេះមិនត្រូវបានទទួលយក លោក អៀង សារី នឹងត្រូវបានបដិសេធមិនផ្តល់ឱ្យនូវឱកាសធ្វើការឆ្លើយតបទៅនឹងទឡ្ហីករណ៍ទាំងឡាយដែលបានដាក់រួចហើយ នៅក្នុងចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

**អាស្រ័យហេតុនេះ** តាមហេតុផលដូចដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. អនុញ្ញាតឱ្យមេធាវីការពារក្តីធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ឬ

ខ. អនុញ្ញាតឱ្យមេធាវីផ្តល់ទឡ្ហីករណ៍ដោយផ្ទាល់មាត់ជាសាធារណៈ។

---

[១២] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៦១។

[១៣] *ដូចជើងទំព័រខាងលើ* (គូសបញ្ជាក់បន្ថែម) កថាខណ្ឌ៦៣។

**ការឆ្លើយតប**

**ក. ដើមបណ្តឹងរដ្ឋប្បវេណីរួមបញ្ចូលគ្នាតែមួយនូវឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

៣. អង្គបុរេជំនុំជម្រះ "បានធ្វើការសន្និដ្ឋានថា អំពើរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មសង្គ្រាមមុន ឆ្នាំ ១៩៧៥"[១៤]។ អង្គបុរេជំនុំជម្រះក៏បានយល់ឃើញ "ថា ត្រឹមឆ្នាំ ១៩៧៥ អំពើរំលោភសេពសន្ថវៈ មិនមានក្រោមច្បាប់អន្តរជាតិតាមការយល់ឃើញផ្ទាល់ខ្លួន ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលបានរៀបរាប់នោះទេ"[១៥]។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ដោយសារតែឧក្រិដ្ឋកម្ម សង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាឧក្រិដ្ឋកម្មដែលមានលក្ខណៈប្រហាក់ប្រហែល គ្នា ឧក្រិដ្ឋកម្មមួយដែលសមស្របដាក់បញ្ចូលទៅក្នុងប្រភេទឧក្រិដ្ឋកម្មមួយ ត្រូវតែសមស្របនឹង ដាក់បញ្ចូលទៅក្នុងប្រភេទឧក្រិដ្ឋកម្មមួយទៀតផងដែរ"[១៦]។ ការអះអាងនេះមិនត្រឹមត្រូវទេ។ ទី មួយ ការប៉ុនប៉ងរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការប្រៀបធៀបឧក្រិដ្ឋកម្ម និងឧក្រិដ្ឋកម្មប្រឆាំង នឹងមនុស្សជាតិរំលោភលើបម្រាមចំពោះការប្រៀបធៀបទាំងនៅក្នុងច្បាប់រដ្ឋប្បវេណី និងនៅក្នុង ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[១៧]។ ទីពីរ ដូចដែលបានលើកឡើងដោយ អង្គបុរេជំនុំជម្រះ "អំពើរំលោភ

---

[១៤] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ លេខ D427/1/30 ("សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ"), កថាខណ្ឌ៣៦៧។

[១៥] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ៣៧០។

[១៦] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ១០, ១៤។

[១៧] *សូមមើល* លក្ខន្តិកតុលាការព្រហ្មទណ្ឌអន្តរជាតិ, មាត្រា២២(២) ដែលមានចែងផ្នែកដែលពាក់ព័ន្ធថា "និយមន័យនៃបទ ល្មើសព្រហ្មទណ្ឌត្រូវតែបកស្រាយអធិប្បាយឲ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយការពន្យល់ប្រៀបធៀបឡើយ"។ ជាងនេះទៅទៀត "តុលាការជាតិក្នុងប្រទេសនានា (ដោយឡែកនៅក្នុងប្រទេសដែលប្រើប្រព័ន្ធស៊ីវិលឡូ) រួមទាំងតុលាការ អន្តរជាតិផង ជាធម្មតាលែងអនុវត្ត [ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ] ដោយការពន្យល់ប្រៀបធៀបទៀតហើយ"។ នៅក្នុងច្បាប់ជាតិ ការហាមឃាត់មិនឲ្យអនុវត្តវិធាននៃបទល្មើសដោយការការពន្យល់ប្រៀបធៀប... មានដើមកំណើតមកពីតម្រូវការចាំបាច់ឲ្យ មានការការពារប្រជាពលរដ្ឋ និងដោយឡែក ដើម្បីទប់ស្កាត់មិនឲ្យពួកគេត្រូវបានផ្តន្ទាទោស ដោយសារសកម្មភាពដែលពួកគេ បានប្រព្រឹត្តដែលមិនត្រូវបានចាត់ទុកថាខុសច្បាប់ ...។ គោលការណ៍ស្រដៀងគ្នានេះ ក៏អនុវត្តនៅក្នុងច្បាប់អន្តរជាតិដែរ។ លក្ខណៈសមហេតុសមផលនៃគោលការណ៍នេះគឺថា តម្រូវការចាំបាច់ឲ្យការការពារដល់បុគ្គលចំពោះការប្រព្រឹត្តមិនត្រឹមត្រូវពី សំណាក់រដ្ឋអំណាច ឬតុលាការ ..." CASSESE, INTERNATIONAL CRIMINAL LAW 2ND ED, ត្រង់ទំព័រ៥៨។

សេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមានធាតុផ្សំសំខាន់ៗ ដូចឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវដែលជាផ្នែកមួយ នៃ "ការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ"។ អំពើរំលោភសេពសន្ថវៈដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិកំណត់និយមន័យ មិនមានធាតុផ្សំបែបនេះទេ"[១៨]។ ដូចគ្នាដែរ អំពើរំលោភសេពសន្ថវៈដែលត្រូវបានកំណត់និយមន័យក្រោមឧក្រិដ្ឋកម្មសង្គ្រាមមិនមានធាតុផ្សំបែបនេះទេ។ អង្គបុរេជំនុំជម្រះសន្និដ្ឋានដោយយល់ឃើញថា "ដោយសារធាតុផ្សំនៃបទល្មើសទាំងពីរប្រភេទមិនដូចគ្នាបេះបិទនោះ បទល្មើសជាតិ និងបទល្មើសអន្តរជាតិត្រូវបានចាត់ទុកជាបទល្មើសដាច់ពីគ្នា"[១៩]។ ដូចគ្នាដែរ ដោយសារធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ប្រភេទមិនដូចគ្នាបេះបិទនោះ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានចាត់ទុកជាបទល្មើសដាច់ពីគ្នា។ ប្រសិនបើការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺដើម្បីឲ្យមានការរួសទាញណាមួយ - ដែលសហមេធាវីការពារក្ដីលើកឡើងថា ការអះអាងនោះមិនអញ្ជឹងទេ - ពេលនោះ ការអះអាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគ្រាន់តែគាំទ្រអង្គហេតុដែលថា នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចំណងទាក់ទងគឺចាំបាច់រវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ[២០]។

៤. ដើមបណ្ដឹងរដ្ឋប្បវេណីអះអាងថា "ឧក្រិដ្ឋកម្មនានាដែលត្រូវបានចុះបញ្ជីថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិត្រូវគេយល់ឃើញថា ឧក្រិដ្ឋកម្មដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ដោយគិតដល់ការរីកចម្រើននៃ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ប៉ុន្តែត្រូវបានកំណត់គោលដៅប្រឆាំងនឹងក្រុមមនុស្សផ្សេងទៀត"[២១]។ ធម្មនុញ្ញតុលាការយោធាអន្តរជាតិមិនចាត់ទុកអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ធម្មនុញ្ញតុលាការយោធាអន្តរជាតិចែងថា តុលាការយោធាអន្តរជាតិមានយុត្តាធិការ

---

[១៨] សាលដីការបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៣៧០។

[១៩] *ដូចជើងទំព័រខាងលើ*។

[២០] *សូមមើលជាឧទាហរណ៍*, ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១, ឯកសារលេខ E95/4។

[២១] ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, កថាខណ្ឌ១៥។

លើ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ ពោលគឺ ការសម្លាប់មនុស្ស ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសភាព ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងទៀត ...[២២] ។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ការប្រើប្រាស់ពាក្យថា "ពោលគឺ" បង្ហាញថា បញ្ជីនេះមិនពិនិត្យជិតដល់នោះទេ[២៣]។ ការអះអាងនេះមិនត្រឹមត្រូវនោះទេ។ ពាក្យ "ពោលគឺ" ដូចដែលបានកំណត់និយមន័យដោយវចនានុក្រម Black's Law Dictionary "បង្ហាញពីឈ្មោះនានាដែលត្រូវរួមបញ្ចូល។ ផ្ទុយទៅវិញ ពាក្យ *ដោយរួមបញ្ចូល* បញ្ជាក់ពីបញ្ជីឈ្មោះមួយផ្នែក និងបង្ហាញថា នៅមានឈ្មោះផ្សេងទៀតដែលមិនត្រូវបានបញ្ចូលក្នុងបញ្ជីនៅឡើយទេ"[២៤]។

៥. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ច្បាប់ជាតិមួយចំនួន និងសៀវភៅក្បួនយោធា ប្រមូលចងក្រងអំពើរំលោភសេពសន្ថវៈ រឺអំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មសង្គ្រាមនៅក្នុងយុត្តាធិការថ្នាក់ជាតិជាច្រើន គិតត្រឹមឆ្នាំ ១៩៧៥[២៥]។ ពុំមានសៀវភៅក្បួនយោធាណាមួយដែលដើមបណ្តឹងរដ្ឋប្បវេណីបានដកស្រង់បានប្រមូលចងក្រងអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិយ៉ាងច្បាស់លាស់។ ដូចដែលបានពន្យល់ខាងលើ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មជាតិមិនមានធាតុផ្សំដូចគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ហេតុដូច្នេះ ត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋដាច់ពីគ្នា។

**ខ. ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចសំអាងលើឧក្រិដ្ឋបនីយកម្មរបស់យុត្តាធិការថ្នាក់ជាតិចំពោះអំពើរំលោភសេពសន្ថវៈដើម្បីបង្ហាញភស្តុតាងថា អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានឡើយ**

៦. អង្គបុរេជំនុំជម្រះបានយល់ឃើញថា ការកំណត់ជាបទល្មើសនូវអំពើរំលោភសេពសន្ថវៈនៅក្នុងក្រមព្រហ្មទណ្ឌជាតិមិនបង្ហាញថា អំពើរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

---

[២២] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ, មាត្រា៦(គ) (គូសបញ្ជាក់បន្ថែម)។

[២៣] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ១៥។

[២៤] វចនានុក្រម BLACK'S LAW DICTIONARY 1044 (កែប្រែលើកទី៧ ឆ្នាំ ១៩៩៩)។

[២៥] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ២៦។

នោះទេ”[២៦]។ ដើមបណ្ដឹងរដ្ឋប្បវេណីដកស្រង់ “ច្បាប់គ្រប់គ្រងការជំនុំជម្រះក្ដីឧក្រិដ្ឋជនសង្គ្រាម” របស់ចិន (“ច្បាប់ចិន”)[២៧] និងរឿងក្ដី *Takashi*[២៨] ធ្វើជាភស្តុតាង បង្ហាញថា “ការចោទប្រកាន់អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតឡើងរួចហើយ នៅក្នុងយុត្តាធិការថ្នាក់ជាតិនាដើមទសវត្សរ៍ឆ្នាំ ១៩០០”[២៩]។ ទីមួយ ច្បាប់ចិនមិនបានចែងពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *នៅក្នុង*នោះ ទេ។ ជំនួសទៅវិញ ការអត្ថាធិប្បាយដែលដើមបណ្ដឹងរដ្ឋប្បវេណីបានយកធ្វើជាសំអាង លើកឡើងថា ច្បាប់ចិនបញ្ចូលនៅក្នុងយុត្តាធិការជាកម្មវត្ថុរបស់ខ្លួននូវបទល្មើសទាំងឡាយដែល “ឆ្លើយតបផ្នែកស្មារតីទៅនឹងទស្សនាទាននៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[៣០]។ ផ្ទុយទៅវិញ ការអត្ថាធិប្បាយលើកឡើងថា ច្បាប់ចិន បានអនុវត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងឧក្រិដ្ឋកម្មសង្គ្រាម*នៅក្នុងនោះ*[៣១]។

៧. ទីពីរ នៅក្នុងរឿងក្ដី *Takashi*[៣២] Takashi Sakai ត្រូវបានចោទប្រកាន់ ជំនុំជម្រះទោស និងរកឃើញថាមានពិរុទ្ធ*ដែលក្នុងចំណោមនោះ* ការជំរុញ ឬអនុញ្ញាតឲ្យអ្នកក្រោមបង្គាប់ប្រព្រឹត្តអំពើនានារួមមានអំពើរំលោភសេពសន្ថវៈទៅលើស្ត្រីពីរនាក់[៣៣]។ តុលាការនេះត្រូវបានគេដកស្រង់ថា

---

[២៦] សាលដីការបស់ អ.ប.ជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៧០។

[២៧] ចម្លើយតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី, កថាខណ្ឌ២០។

[២៨] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ២៣។

[២៩] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ២០។

[៣០] ច្បាប់គ្រប់គ្រងសវនាការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាម ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៤៦ នៅក្នុងសវនាការជំនុំជម្រះទោសឧក្រិដ្ឋជនសង្គ្រាមដែលត្រូវបានជ្រើសរើស និងរៀបចំដោយគណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម, ក្រុងឡុងដ៍ (ឆ្នាំ ១៩៤៦) ក្បាលទី XIV, ឧបសម្ព័ន្ធ, *អាចរកបាននៅគេហទំព័រ៖* http://www.loc.gov/rr/frd/Military_Law/pdf/Law-Reports_Vol-14.pdf។

[៣១] *ដូចជើងទំព័រខាងលើ*។

[៣២] សវនាការ Takashi Sakai, តុលាការឧក្រិដ្ឋកម្មសង្គ្រាមនៃក្រសួងការពារជាតិចិន, ក្រុងណានគីង, ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៤៦, នៅក្នុងសវនាការឧក្រិដ្ឋជនសង្គ្រាមដែលត្រូវបានជ្រើសរើស និងរៀបចំដោយ ដោយគណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម, ក្រុងឡុងដ៍ (ឆ្នាំ ១៩៤៦) ក្បាលទី XIV, ឧបសម្ព័ន្ធ, *អាចរកបាននៅគេហទំព័រ៖* http://www.loc.gov/rr/frd/Military_Law/pdf/Law-Reports_Vol-14.pdf ។

[៣៣] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ១-២។

បានសន្និដ្ឋានថា “ក្នុងការជំរុញ ឬអនុញ្ញាតឲ្យអ្នកក្រោមបង្គាប់ ... ប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ បានរំលោភបំពានទៅលើអនុសញ្ញាទីក្រុងឡាអេស្តីពីច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមនៅលើដីគោក និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩” ។ “បទល្មើសគឺជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[៣៤]។ ដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របថា តុលាការក្នុងរឿងក្តី *Takashi* មិនបានបកស្រាយឲ្យបានច្បាស់ពីធាតុផ្សំខុសៗគ្នានៃឧក្រិដ្ឋសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ[៣៥]។ ដោយមិនមានសាលក្រមដែលបង្ហាញសំអាងហេតុត្រឹមត្រូវនោះ គេមិនអាចសន្និដ្ឋានបានថា Takashi ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលត្រូវបានអនុវត្តនៅ អ.វ.ត.ក ទេ។ ជាងនេះទៀត តុលាការនេះបានសំអាងការផ្តន្ទាទោសរបស់ខ្លួនទៅលើអនុសញ្ញាទីក្រុងឡាអេស្តីពីច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមនៅលើដីគោក និងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩២៩។ ច្បាប់ទាំងនេះមិនបានកំណត់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាបទល្មើសទេ។

៨. ជាចុងក្រោយ ច្បាប់មួយ (បន្ថែមទៅលើច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង) ដែលការផ្តន្ទាទោសអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលផ្អែកលើធាតុផ្សំមិនច្បាស់លាស់ មិនបានបង្ហាញពីការអនុវត្តរបស់រដ្ឋជាលក្ខណៈទូលំទូលាយ និង*សច្ចធាណ៍ធម្មានុរូប* *(opinio juris)* ទេ។ អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនមានអត្ថិភាពចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ។

### គ. ដើមបណ្តឹងរដ្ឋប្បវេណីធ្វើការប៉ាន់ស្មាន នៅពេលពិចារណាពីស្ថានភាពនៃការរំលោភសេពសន្ថវៈនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៩. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ទាំងបញ្ជីឈ្មោះ “សមាជិកពេញសិទ្ធ និងសមាជិកបម្រុងរបស់តុលាការ” ទាំងបញ្ជីឈ្មោះ “មេធាវីដើមបណ្តឹង” នៅតុលាការយោធាអន្តរជាតិ មិនមានអ្នកចូលរួមជាស្ត្រីភេទទេ ហើយថា នេះអាចជាកត្តាមួយគួរឲ្យកត់សម្គាល់ នៅក្នុងការលុបចោលដោយខ្ជីខ្ជានូវ

---

[៣៤] *ដូចដើងទំព័រខាងលើ,* កថាខណ្ឌ៧។

[៣៥] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ២៤។

អំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[៣៦]។ ការអះអាងបែបនេះរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺផ្អែកលើការប៉ាន់ស្មានសុទ្ធសាធ។ ការប៉ាន់ស្មានបែបនេះគឺមិនពាក់ព័ន្ធទេ នៅពេលពិចារណាពីស្ថានភាពនៃអំពើរំលោភសេពសន្ថវៈ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

**គ. ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង មិនបានចាត់ទុកអំពើរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ**

១០. អង្គបុរេជំនុំជម្រះយល់ឃើញថា "មកត្រឹមឆ្នាំ ១៩៧៥ អំពើរំលោភសេពសន្ថវៈមិនទាន់មាននៅក្នុងច្បាប់អន្តរជាតិថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ"[៣៧]។ អង្គជំនុំជម្រះបានសម្រេចបែបនេះបន្ទាប់ពីបានពិនិត្យទៅលើ ក្រម Lieber, The Oxford Manual, បទបញ្ញាទីក្រុងឡាអេ, គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កសង្គ្រាម និងស្តីពីការអនុវត្តការផ្តន្ទាទោសៈ របាយការណ៍ដែលបានដាក់ជូនអង្គសន្និសីទសន្តិភាពបឋម, ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង, ធម្មនុញ្ញតុលាការយោធាអន្តរជាតិ, សាលក្រមរបស់តុលាការយោធាអន្តរជាតិ, ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់តុលាការយោធាអន្តរជាតិសម្រាប់ចុងបូព៌ា ("IMTFE"), សាលក្រមតុលាការ IMTFE និងរឿងក្តី *ប្រទេសស៊ីប្រ៊ុស តទល់នឹង ប្រទេសទួរគី*[៣៨]។

១១. ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ដោយសារមិនមានការវិវឌ្ឍនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិរវាងធម្មនុញ្ញតុលាការយោធាអន្តរជាតិដែលមិនបានចាត់ទុកអំពើរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងដែលបានចាត់ទុកអំពើរំលោភ

[៣៦] *ដូចជើងទំព័រខាងលើ,* កថាខណ្ឌ១៧។ ឯកសារយោងដែលដើមបណ្តឹងរដ្ឋប្បវេណីយកមកសំអាងមិនបាននិយាយពី "បញ្ជីឈ្មោះអ្នកតំណាង និងជំនួយការ" នៃសន្និសីទអន្តរជាតិស្តីពីសវនាការតុលាការយោធា, ក្រុងឡុងដ៍ ឆ្នាំ ១៩៤៥" (ដែលដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនូវលេខាស្ត្រីពីរនាក់ប៉ុណ្ណោះ) និងមិនបាននិយាយពីស្ត្រីទាំងនោះទាល់តែសោះ។

[៣៧] សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៧១។

[៣៨] *រឿងក្តីប្រទេសស៊ីប្រ៊ុស តទល់នឹង ប្រទេសទួរគី,* ពាក្យសុំរបស់គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុបលេខ 6780/74 និង 9650/75 (ឆ្នាំ ១៩៨២) 4 E.H.R.R. កថាខណ្ឌ៤៨២-៨៣។

សេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ អំពើរំលោភសេពសន្ថវៈពិតជាមានអត្ថិភាពជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅខែ សីហា ឆ្នាំ ១៩៤៥ មែន[៣៩]។ ច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវបានបង្កើតឡើងតាមរយៈការអនុវត្តរបស់រដ្ឋយ៉ាងទូលំទូលាយ និង*សច្ចធាណ៍ធម្មានុរូប* *(opinion juris)* មិនមែនតាមរយៈការសម្រេចពីស្ថានភាពបច្ចុប្បន្ន ឬអនាគតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ រួចយកវាមកអនុវត្តបែបប្រតិសកម្មនោះទេ។

១២. អង្គបុរេជំនុំជម្រះយល់ឃើញថា ទោះបីច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងបានកំណត់អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏ដោយ តែចំណុចនេះមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ពីការអនុវត្តរបស់រដ្ឋ និង *សច្ចធាណ៍ធម្មានុរូប* *(opinio juris)* ថាអំពើរំលោភសេពសន្ថវៈត្រូវបានចាត់ទុកថាជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះទេ[៤០]។ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា "ការចងក្រងនៃអំពើរំលោភសេពសន្ថវៈ ថាជាបទឧក្រិដ្ឋកម្មដែលមានឈ្មោះក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *តែមួយ* បង្ហាញអំពីទស្សនៈរបស់សហគមន៍ដែលថា អំពើរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[៤១]។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងមិនអាចយកមកធ្វើជាសំអាង ដើម្បីបង្ហាញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិបានទេ ដោយសារថាតុលាការរបស់ពួកសម្ព័ន្ធមិត្រ និងអាល្លឺម៉ង់ដែលអនុវត្តច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងត្រូវបានចាត់ទុកថាជា "តុលាការក្នុងស្រុក ដោយប្រើប្រាស់ច្បាប់ក្នុង (ក្រុង)"[៤២] និង "ក្រោយពេល

---

[៣៩] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ១៨។

[៤០] សាលដីការបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៦៨, ៣៧១។

[៤១] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ២៨។

[៤២] Egon Schwelb, *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (Crimes Against Humanity)* 23 B.Y.B. INT'L L. 178, 218-19 (ឆ្នាំ ១៩៤៦)។ *សូមមើលផងដែរ* Attila Bogdan, *ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល នៅក្នុងការអនុវត្ត "សហឧក្រិដ្ឋកម្មរួម" នៅក្នុងយុត្តាធិការនៃតុលាការមិនអចិន្ត្រៃយ៍សម្រាប់អតីតប្រទេសយូហ្គោស្លាវី (Individual Criminal Responsibility in the Execution of a "Joint Criminal Enterprise" in the Jurisprudence of the* ad hoc *International Tribunal for the Former Yugoslavia)* 6 INT'L CRIM. L. REV. 63, 110 (ឆ្នាំ ២០០៦)។ ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង "មិនអាចត្រូវបានចាត់ទុកជាផ្នែកនៃច្បាប់អន្តរជាតិទេ ដោយហេតុថាច្បាប់នេះត្រូវបានអនុម័តដោយអាជ្ញាធរនីតិបញ្ញត្តិគ្រប់គ្រងប្រទេសអាល្លឺម៉ង់ (ក្រុមប្រឹក្សាគ្រប់គ្រងរបស់សម្ព័ន្ធមិត្ត)"។ ហេតុនេះហើយបានជាសាលក្រមដែលចេញអនុលោមតាមច្បាប់លេខ ១០

ចប់សង្គ្រាមលោកលើកទីពីរភ្លាម និយមន័យនៃពាក្យថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ [របស់តុលាការយោធាអន្តរជាតិ] ត្រូវបានចាត់ទុកថាជាសេចក្តីថ្លែងការនៃច្បាប់អន្តរជាតិដែលត្រូវបានទទួលយកបានជាច្រើនបំផុត"[៤៣]។ គោលការណ៍ Nuremberg (ដែលមិនបានចាត់ទុកអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ឆ្លុះបញ្ចាំងនូវការយល់ដឹងនេះ[៤៤]។

១៣. ដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ទៅលើខ្លឹមសារ នៃការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះដែលថាការផ្តន្ទាទោសអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គឺជាទឡ្ហីករណ៍មួយប្រឆាំងនឹងអត្ថិភាពរបស់វានៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៤៥]។ ដើមបណ្តឹងរដ្ឋប្បវេណីមានកំហុសឆ្គងនៅក្នុងការជំទាស់របស់ខ្លួន។ ការណ៍ដែលថា អំពើរំលោភសេពសន្ថវៈមិនត្រូវបានជំនុំជម្រះទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងបង្ហាញថា មិនមានការអនុវត្តរបស់រដ្ឋយ៉ាងទូលំទូលាយគ្រប់គ្រាន់ដើម្បីបង្ហាញថា វាជាវិធានមួយរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះទេ។

### ង. អង្គជំនុំជម្រះសាលាដំបូងពុំអាច "កំណត់បទចោទឡើងវិញ" បានឡើយទៅលើអំពើរំលោភសេពសន្ថវៈដែលពុំស្ថិតក្នុងបរិបទនៃការរៀបការដោយបង្ខំ ដើម្បីឆ្លុះបញ្ចាំងអំពីការប្រើប្រាស់អំពើរំលោភសេពសន្ថវៈជាផ្នែកមួយនៃ "គោលនយោបាយបោសសម្អាតខ្មាំង"

---

របស់ក្រុមប្រឹក្សាគ្រប់គ្រងនេះ មិនបានក្លាយជាយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដែលមានសុពលភាពទេ ..." (គូសបញ្ជាក់បន្ថែម)។

[៤៣] *សូមមើល* Stuart Ford, *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ តើមានទំនាក់ទំនងទៅនឹងជម្លោះប្រដាប់អាវុធឬទេ? (Crimes Against Humanity at The Extraordinary Chambers in the Courts of Cambodia: Is a Connection with Armed Conflict Required?)*, 24 UCLA PAC. BASIN L.J. 125, 148, 151 (ឆ្នាំ ២០០៦-២០០៧)។

[៤៤] គោលការណ៍តុលាការ Nuremberg, គោលការណ៍ VI(គ)។

[៤៥] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ២៧-២៨។

១៤. ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចោទប្រកាន់ជនជាប់ចោទពីអំពើរំលោភសេពសន្ថវៈ ដែលពុំមែនជាបទល្មើសស្ថិតក្នុងបរិបទនៃការចេញបទបញ្ជាឱ្យរៀបការ[៤៦]។ ដីកាដំណោះស្រាយបានយល់ឃើញថា អំពើរំលោភសេពសន្ថវៈ ពុំមែនជាបទល្មើសដែលមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា យកមកប្រើប្រាស់ដើម្បីអនុវត្តផែនការរួមដែលត្រូវបានចោទប្រកាន់នោះឡើយ[៤៧]។ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទពីអំពើរំលោភសេពសន្ថវៈ ត្រឹមតែនៅក្នុងបរិបទនៃគោលនយោបាយស្ដីពីការចេញបទបញ្ជាឱ្យរៀបការប៉ុណ្ណោះ។ តាមការពិត ដើមបណ្ដឹងរដ្ឋប្បវេណីកំពុងស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង កាត់សេចក្ដីជនជាប់ចោទពីបទល្មើសដែលពួកគាត់ពុំបានជាប់ចោទ។ ទង្វើនេះជាការរំលោភវិធានផ្ទៃក្នុង។ វិធាន ៩៨(២) ចែងថា៖ "សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណា ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទបានឡើយ"។ ទីមួយ ការចោទប្រកាន់អំពីគោលនយោបាយនៃអំពើរំលោភសេពសន្ថវៈ ដែលពុំស្ថិតនៅក្នុងបរិបទនៃការចេញបទបញ្ជាឱ្យរៀបការគឺជាការពន្លាត "អង្គហេតុ" ឱ្យហួសពីអ្វីដែលមានក្នុងដីកាដំណោះស្រាយ។ ទីពីរ អង្គជំនុំជម្រះសាលាដំបូងពុំអាចកែប្រែដីកាដំណោះស្រាយដោយដាក់បញ្ចូលគោលនយោបាយនៃអំពើរំលោភសេពសន្ថវៈ ដែលពុំស្ថិតនៅក្នុងបរិបទនៃការចេញបទបញ្ជាឱ្យរៀបការបានឡើយ ដោយហេតុថា គោលនយោបាយនៃការរំលោភសេពសន្ថវៈពុំមែនជាបទល្មើស ដែលមាននៅក្នុងដីកាដំណោះស្រាយ។

១៥. បន្ថែមពីលើនេះ ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបន្ថែមអង្គហេតុ និងទទួលស្គាល់ភស្តុតាងដែលខ្លួនអះអាងថាជាភស្តុតាងដែលបញ្ជាក់ថា **ក.**"ចារីពុំបានទទួលទោសពី

[៤៦] *ដូចដើងទំព័រខាងលើ*, កថាខណ្ឌ៣២-៤១។

[៤៧] ដីកាដំណោះស្រាយ, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០, លេខឯកសារ D427, កថាខណ្ឌ ១៤២៨ ចែងថា "ជនដែលត្រូវបានចោទប្រកាន់ថា មានអំពើ "ខុសសីលធម៌" ត្រូវបានចោទចូលប្រភេទ "សមាសភាពមិនល្អ" ឬ "ខ្មាំង" ដែលជារឿយៗត្រូវបានលត់ដំ ឬសម្លាប់"។

អំពើរំលោភសេពសន្ថវៈឡើយ ប្រសិនបើពួកគេត្រូវបានចាត់ទុកថាជាមនុស្សបដិវត្តន៍ដ៏មោះមុត"[48] **ខ.**"ស្ត្រី ដែលត្រូវបានខ្មែរក្រហមចាត់ទុកជា "ខ្មាំង" និង/ឬ "សមាសភាពមិនល្អ" តែងបានរងគ្រោះពីអំពើរំលោភសេពសន្ថវៈមុនពេលសម្លាប់"[49] និង **គ.**ចារីនៅមន្ទីរសន្តិសុខសង់ ត្រូវបានចាប់ខ្លួនតែមួយសប្តាហ៍ប៉ុណ្ណោះ រួចក៏ដោះលែងវិញ។ ចារីទាំងអស់នេះបានបន្តតួនាទីរបស់ខ្លួនឡើងវិញក្រោយពេលដោះលែង ហើយពួកគេបានប្រើអំណាចបញ្ជាឲ្យបង្អត់អាហារជនរងគ្រោះដោយអំពើរំលោភសេពសន្ថវៈនោះ[50]។

១៦. អង្គជំនុំជម្រះសាលាដំបូងត្រូវតែបដិសេធសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ "អង្គហេតុ" ទាំងអម្បាលម៉ាននេះពុំបង្កើតបានជាផ្នែកមួយនៃដីកាដំណោះស្រាយឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានទទួលស្គាល់ដែរថា"អង្គហេតុ"ទាំងនេះត្រូវបានលុបចេញពីដីកាដំណោះស្រាយ[51]។ ការទទួលយកសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាការរំលោភទៅលើវិធាន៩៨(២)។ បញ្ហានេះពុំមែនជាបញ្ហានៃការកំណត់បទចោទឡើងវិញឡើយ ប៉ុន្តែគឺជាបញ្ហានៃការដាក់បន្ថែមបទចោទថ្មី។

**អាស្រ័យហេតុនេះ** តាមហេតុផលដូចដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើរបស់ ក.ស.ព ស្នើសុំកំណត់បទចោទសាជាថ្មី ទៅលើអង្គហេតុទាំងឡាយដែលបង្កើតបានជាអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលនូវក្តីគោរពដ៏ស្មោះស្ម័គ្រអំពីយើងខ្ញុំ។

| អាង ឧត្តម | Michael G. KARNAVAS |
|---|---|

[48] ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី, កថាខណ្ឌ៣៣។

[49] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ៣៥។

[50] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ៣៨។

[51] *ដូចជើងទំព័រខាងលើ*, កថាខណ្ឌ៤០។

សហមេធាវីរបស់លោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា **ថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១១**

**សំណើរបស់លោក អៀង សារី សុំអនុញ្ញាតឆ្លើយតប និងការឆ្លើយតបទៅនឹង “ចម្លើយតប” របស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

Original EN: 00721466-00721473